**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..ធ៥៣.០១៩-.៣៩៣..ស.ជ..ណ.......

*ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩*

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ លើកទី៤៧

នៅថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៩ វេលាម៉ោង ៣:០០ រសៀល ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុលើកទី៤៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល និងជាប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ។ អង្គប្រជុំបានពិភាក្សាទៅលើស្ថានភាពសេដ្ឋកិច្ច និងការអនុវត្តគោលនយោបាយរូបិយវត្ថុនៅត្រីមាសទី១ និងទិសដៅនាត្រីមាសខាងមុខ។ នៅត្រីមាសទី១ ឆ្នាំ២០១៩នេះ សូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗបង្ហាញវឌ្ឍនភាពល្អ។ អតិផរណាមានកម្រិតទាបជាមធ្យម ១,៩% អត្រាប្តូរប្រាក់ ៤.០១៧រៀលក្នុងមួយដុល្លារអាមេរិក ហើយទុនបម្រុងអន្តរជាតិដុលបានកើនឡើងជាបន្តបន្ទាប់ ដែលអាចធានាការនាំចូលទំនិញនិងសេវាបានប្រមាណ ៥ខែនាគ្រាបន្ទាប់។

ដើម្បីបន្តរក្សាបាននូវស្ថិរភាពថ្លៃ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ បានសម្រេចបន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ដូចខាងក្រោម ៖

១/- បន្តប្រកាន់យករបបអត្រាប្តូរប្រាក់ដែលមានស្ថិរភាពដោយធ្វើអន្តរាគមន៍ចាំបាច់ ផ្អែកលើការប្រែប្រួលនៃសេដ្ឋកិច្ច ដើម្បីបន្តពង្រឹងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល

២/- រក្សាស្ថិរភាពអត្រាការប្រាក់ LPCO និងផ្គត់ផ្គង់បរិមាណសន្ទនីយភាពជាប្រាក់រៀល ៨០០ ប៊ីលានរៀល ក្នុង១ខែ ឬទៅតាមការវាយតម្លៃលើតម្រូវការសេដ្ឋកិច្ច

៣/- បន្តលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយ តាមរយៈការបង្កើនការយល់ដឹងរបស់សាធារណជនពីសារៈសំខាន់ និងតួនាទីប្រាក់រៀលនៅក្នុងសេដ្ឋកិច្ចនិងសង្គម និង

៤/- បន្តតាមដាននិងវាយតម្លៃជាប្រចាំលើការអនុវត្តតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពី ការតម្រូវឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានប្រាក់កម្ចីយ៉ាងហោច ១០% ជាប្រាក់រៀល។

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ប្រធានគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ**

ជា_ចាន់តូ

**ចម្លងជូន ៖**
- សមាជិកគណៈកម្មាធិការគោលនយោបាយរូបិយវត្ថុ
- ឯកសារ-កាលប្បវត្តិ